01320155 **Declassified to Public**
**12 June 2020**

ឯកសារ D319/1

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 19-Aug-2016, 09:31
CMS/CFO: Ly Bunloung

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

សំណុំរឿងលេខ: ០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស

នៅចំពោះមុខ: សហចៅក្រមស៊ើបអង្កេត

កាលបរិច្ឆេទឯកសារ: ថ្ងៃទី៥ ខែសីហា ឆ្នាំ២០១៦

ភាសាដើម: អង់គ្លេស

ចំណាត់ថ្នាក់ឯកសារ: សម្ងាត់

---

# សេចក្តីសម្រេចលើសំណើសុំឈ្មោះ និងរហស្សនាមនៃសាក្សីក្នុងសំណុំរឿង ០០២

---

**<u>ផ្ញើជូន៖</u>**

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តី អោ អាន**
មុំ លុជ្ជ
Richard ROGERS
Göran SLUITER

**មេធាវីការពារក្តី យឹម ទិត្យ**
សូ មូស្សេទ្ធី
Richard ROGERS
Göran SLUITER
Suzana TOMANOVIĆ

**<u>មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**
ជេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន សុវ៉ន
ទី ស្រីនណា
វ៉ែន ពៅ
Linda BEHNKE
Laure DESFORGES
Herve DIAKIESE
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Beini YE

# I. ប្រវត្តិនីតិវិធី

១. ករណីខ្វែងយោបល់គ្នានៅក្នុងរឿងក្តីនេះត្រូវបានចុះហត្ថលេខានៅថ្ងៃទី២២ ខែកុម្ភៈ និងថ្ងៃទី៥ ខែមេសា ឆ្នាំ២០១៣ ព្រមទាំងនៅថ្ងៃទី២២ ខែមករា ឆ្នាំ២០១៥។

២. នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៦ មេធាវីការពារក្តីលោក យឹម ទិត្យ ("មេធាវីការពារក្តី") បានសរសេរលិខិតមួយច្បាប់ផ្ញើជូនសហចៅក្រមស៊ើបអង្កេត ("ស.ច.ស") ស្នើសុំឈ្មោះសាក្សីពីររូបដែលគ្រោងមកផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង 00២/0២ ក្រោមរហស្សនាមស្តីពីប្រធានបទទាក់ទងនឹងសំណុំរឿង 00៤ ក៏ប៉ុន្តែមេធាវីការពារក្តីពុំមានវិធីណាអាចបញ្ជាក់ថាតើពួកគេប្រាកដជាសាក្សីនៅក្នុងដំណើរការកិច្ចស៊ើបសួរនោះឡើយ[1]។

៣. មេធាវីការពារក្តីសន្និដ្ឋានថា សំណើសុំនេះចាំបាច់ត្រូវធ្វើឡើងដោយសារមូលហេតុសាក្សីចំនួនពីររូបដែលគ្រោងមកផ្តល់សក្ខីកម្មក្រោមរហស្សនាមស្តីពីប្រធានបទទំនប់ត្រពាំងថ្ម និងការប្រព្រឹត្តលើជនជាតិវៀតណាមនៅក្នុងសំណុំរឿង 00២។ ក៏ប៉ុន្តែវាពុំបានបង្ហាញច្បាស់ថាតើពួកគេគឺជាសាក្សីដែលបានលាតត្រដាងដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("ស.ច.ស.អ")[2]។ មេធាវីការពារក្តីលើកឡើងថា ទោះបីជារហស្សនាមមានភាពចាំបាច់ដូចគ្នានឹងភាពជាសាធារណៈក៏ដោយ ក៏រហស្សនាមទាំងនេះពុំមែនប្រើប្រាស់ក្នុងគោលបំណងរក្សាអត្តសញ្ញាណនៃសាក្សីបែបនេះជាការសម្ងាត់ពីមេធាវីការពារក្តីនោះទ[3]។

៤. ជាដំបូងឡើយ យើងបានទទួលសំណើសុំឈ្មោះសាក្សីក្នុងសំណុំរឿង 00២ ដែលគ្រោងមកផ្តល់សក្ខីកម្មក្រោមរហស្សនាម ហើយដែលត្រូវបានលាតត្រដាងចេញពីក្នុងដំណើរការស៊ើបសួរដែលកំពុងស៊ើបអង្កេតពាក់ព័ន្ធនឹងសំណុំរឿង 00៤ នៅថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦[4]។

---

[1] សំណុំរឿង 00៤ ឯកសារ D319 *សំណើរបស់ យឹម ទិត្យ សុំការបង្ហាញអត្តសញ្ញាណ 2-TCW-876 និង 2-TCCP 234* ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៦ ("សំណើសុំ") ទំព័រ ១។

[2] សំណើសុំ ទំព័រ ១។

[3] *ដូចខាងលើ*។

[4] សំណុំរឿង 00៤ ឯកសារ D300 *សំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ៩* ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ កថាខណ្ឌ ១(គ)។

៥. នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៦ យើងបានស្នើសុំការអនុញ្ញាតពីអង្គជំនុំជម្រះសាលាដំបូងឱ្យផ្ដល់ជូនឈ្មោះសាក្សីក្នុងសំណុំរឿង ០០២ ទាំងនោះ ដែលគ្រោងមកសក្ខីកម្មក្រោមរហស្សនាម។ សាក្សីទាំងនេះក៏ជាផ្នែកមួយនៃការស៊ើបអង្កេតនៅក្នុងសំណុំរឿង ០០៣ និង ០០៤ ចំពោះក្រុមមេធាវីការពារក្ដីនីមួយៗ[5]។

៦. នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា រហស្សនាមដែលបានផ្ដល់ជូនសាក្សីក្នុងសំណុំរឿង ០០២ មានបំណងទប់ស្កាត់ការតាមដានពីសារព័ត៌មាននៅមុនពេលពួកគេផ្ដល់សក្ខីកម្ម ហើយវិធានការការពារចំពោះការផ្ដល់សក្ខីកម្មជាក់ស្ដែង ឬចំពោះប្រតិចារឹកដែលបានបង្កើតឡើងក្រោយពេលផ្ដល់សក្ខីកម្មត្រូវបានកំណត់ឡើងក្នុងលក្ខខណ្ឌកម្រិតតិចតួច[6]។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងបានអនុញ្ញាតឱ្យខ្ញុំ "បង្ហាញដល់សមាជិកក្រុមមេធាវីការពារក្ដីទាំងអស់ក្នុងសំណុំរឿង ០០៣ និងសំណុំរឿង ០០៤ [...] នូវរហស្សនាមដែលអង្គជំនុំជម្រះសាលាដំបូងបានដាក់ឱ្យបុគ្គលទាំងនោះដែលត្រូវផ្ដល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០២ ហើយដែលភ័ស្ដុតាងរបស់ពួកគាត់ត្រូវបានផ្ដល់នៅក្នុងសំណុំរឿង ០០៣ និងសំណុំរឿង ០០៤"[7]។ អង្គជំនុំជម្រះបានលើកឡើងបន្ថែមទៀតថា ការរិតត្បិតទាំងអស់ផ្សេងទៀតដូចបានកត់សម្គាល់នៅក្នុងអនុស្សារណៈនៃ ស.ច.ស.អ នឹងយកមកអនុវត្ត ហើយវារក្សាសិទ្ធិក្នុងការលាក់ទុកឈ្មោះដើម្បីផ្ដល់អនុភាពលើវិធានការការពារនៅក្នុងករណីជាក់លាក់នានាប្រសិនបើវាមានលក្ខណៈចាំបាច់នោះ[8]។

៧. អាស្រ័យហេតុនេះ យើងផ្ដល់បញ្ជីឈ្មោះ និងរហស្សនាមនៃសាក្សីក្នុងសំណុំរឿង ០០២/០២ ដែលក៏ជាសាក្សីនៅក្នុងសំណុំរឿង ០០៤ ជូនមេធាវីការពារក្ដីនៅក្នុងឧបសម្ព័ន្ធដែលបានភ្ជាប់ជាមួយនឹងសេចក្ដីសម្រេចមួយនេះរួមជាមួយនឹងលក្ខខណ្ឌ និងការរិតត្បិតដូចខាងក្រោម។

---

[5] សំណុំរឿង ០០៤ ឯកសារ D313 *អនុស្សារណៈសម្ងាត់បំផុតដែល ស.ច.ស.អ ផ្ញើជូនអង្គជំនុំជម្រះសាលាដំបូង* ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៦។

[6] សំណុំរឿង ០០៤ ឯកសារ D313/1 *អនុស្សារណៈសម្ងាត់បំផុតដែលអង្គជំនុំជម្រះសាលាដំបូង ផ្ញើជូន ស.ច.ស.អ* ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៦ ("អនុស្សារណៈនៃអង្គជំនុំជម្រះសាលាដំបូង") កថាខណ្ឌ ២។

[7] អនុស្សារណៈនៃអង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៣។

[8] *ដូចខាងលើ*។


ផ្លូវជាតិលេខ ៤ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ប្រទេសកម្ពុជា ប្រអប់សំបុត្រ ៧១
ទូរស័ព្ទ: (៨៥៥)-២៣-២១៩-៨១៤ ទូរសារ: (៨៥៥)-២៣-២១៩-៨៤១ គេហទំព័រ: www.eccc.gov.kh

៨. សេចក្តីសម្រេចនេះត្រូវបានដាក់ជាភាសាអង់គ្លេស ហើយសំណៅបកប្រែជាភាសាខ្មែរនឹងដាក់ជូនតាមក្រោយ។

**យោងតាមសំអាងហេតុដូចបានលើកឡើងខាងលើ យើង៖**

៩. **អនុញ្ញាតតាមសំណើសុំ**

១០. **បង្គាប់**ឱ្យមេធាវីការពារក្តីរក្សាការសម្ងាត់ចំពោះរាល់ព័ត៌មានទាំងអស់ដែលបានផ្តល់ជូននៅក្នុងឧបសម្ព័ន្ធ

១១. **បង្គាប់**ឱ្យមេធាវីការពារក្តីរក្សាការសម្ងាត់ចំពោះករណីដែលថា សាក្សីដែលមេធាវីការពារក្តីដេញដោលក្នុងតុលាការ ឬ ពិនិត្យមើលឡើងវិញក្រោយសាក្សីទាំងនេះផ្តល់សក្ខីកម្មក៏ជាសាក្សីនៅក្នុងដំណើរការកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣ ផងដែរ

១២. **បង្គាប់**ឱ្យមេធាវីការពារក្តីផ្តល់ឧបសម្ព័ន្ធជូនចំពោះតែសមាជិកនៅក្នុងក្រុមការពារក្តីរបស់ខ្លួនដូចមានឈ្មោះជាផ្លូវការអនុលោមតាមវិធាន ២២(៥) និង ១២ ស្ទួនពីរ (៤) រួមទាំង កម្មសិក្សាការីដែលទទួលការងារជាផ្លូវការ និង

១៣. **បង្គាប់**ឱ្យក្រឡាបញ្ជីធ្វើចំណាត់ថ្នាក់អនុស្សារណៈរបស់ ស.ច.ស.អ លេខ D313 ដាក់ជាឯកសារសម្ងាត់វិញ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៥ ខែសីហា ឆ្នាំ២០១៦

**ចៅក្រម Michael Bohlander**

**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**



ផ្លូវជាតិលេខ ៤ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ប្រទេសកម្ពុជា ប្រអប់សំបុត្រ ៧១
ទូរស័ព្ទ: (៨៥៥)-២៣-២១៩-៨១៤ ទូរសារ: (៨៥៥)-២៣-២១៩-៨៤១ គេហទំព័រ: www.eccc.gov.kh